ព្រឹត្តិបត្រ

សាលារាជធានីភ្នំពេញ

PHNOM PENH CAPITAL CITY NEWSLETTER

ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលថ្មី
និងចំណតក្រោមដីរបស់សាលារាជធានីភ្នំពេញ
ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចតេជោ ហ៊ុន សែន

ឆ្នាំ២០១៦ លេខ១៨ ត្រីមាសទី១ ឆ្នាំទី៣

#៦៩, មហាវិថីព្រះមុនីវង្ស, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
(៨៥៥)២៣-៧២២-០៥៤
(៨៥៥) ២៣-៧២២-០៥៤
www.phnompenh.gov.kh
info@phnompenh.gov.kh

សាលារាជធានីភ្នំពេញ

PHNOM PENH CAPITAL CITY NEWSLETTER

#៦៩, មហាវិថីព្រះមុនីវង្ស, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+៨៥៥)២៣-៧២២-០៥៤
ទូរសារ: (+៨៥៥) ២៣-៧២២-០៥៤,
គេហទំព័រ: www.phnompenh.gov.kh
អ៊ីម៉ែល: info@phnompenh.gov.kh

ឆ្នាំ២០១៦ លេខ១៦ ខែកុម្ភៈ ត្រីមាសទី១ ឆ្នាំទី៣

មាតិកា

- លិខិតជូនពរ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា.........០៤
- លិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា....០៥
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលថ្មី និងចំណតក្រោមដីរបស់សាលារាជធានីភ្នំពេញ ០៦
- ពិធីក្រុងពាលី ឡើងអគាររដ្ឋបាលថ្មី ដែលទើបសាងសង់រួច តាមបែបសាសនា ០៨
- ពិធីសូត្រមន្ត សុំសេចក្តីសុខសេចក្តីចម្រើនក្នុងឆ្នាំថ្មី ឆ្នាំវក អដ្ឋស័ក ពុទ្ធស័ករាជ ២៥៦០ ....១០
- ពិធីអបអរសាទរ ទទួលទេវតាឆ្នាំថ្មី ព្រះនាមមណ្ឌាទេវី ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០ ....១២
- កិច្ចប្រជុំគណៈអភិបាលរាជធានីភ្នំពេញ បន្តដោះស្រាយបញ្ហា និងបម្រើការងារជូនប្រជាពលរដ្ឋ....,......១៤
- រដ្ឋបាលរាជធានីភ្នំពេញ បានបញ្ជាទិញរថយន្តសម្អាត និងលាងធូលី-ដីតាមផ្លូវ..............................១៥
- កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារសិក្សាគម្រោងពង្រឹងសេវារថយន្តក្រុងរបស់JICA.......................១៦
- កិច្ចប្រជុំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កំណត់បែងចែកភារកិច្ចមន្ត្រីក្រោមឱវាទរដ្ឋាករស្វយ័តរថយន្តក្រុង....១៧
- ប្រតិភូរដ្ឋបាលធានីភ្នំពេញជួបប្រជុំពិភាក្សាជាមួយប្រតិភូក្រសួងសាធារណការ និងដឹកជញ្ជូន ១៨
- ធុងសំរាមចល័តចំនួន ២២៦ធុង នឹងដាក់ពង្រាយទៅតាមទីសួនសាធារណៈ និងតាមទីផ្សារនានា......២០
- ប្រតិភូរដ្ឋបាលរាជធានីភ្នំពេញចុះពិនិត្យ និងដោះស្រាយបញ្ហាប្រឈមមួយចំនួន ក្នុងរាជធានីភ្នំពេញ...២២
- ពិធីតែងតាំងមុខតំណែងអភិបាលខណ្ឌសែនសុខថ្មី គឺ លោក ប៉ឹល កុសល ជំនួស លោក លី សាវេត .២៤
- ពិធីចែកម្ជុកសុវត្ថិភាពចំនួន១.០០០ម្ជុកជូនដល់យុវជនកាកបាទក្រហមកម្ពុជា និងសិស្សានុសិស្ស......២៥
- ពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារថ្មី វត្តព្រែកឯង ស្ថិតនៅសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ ២៦

១. សកម្មភាពថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា...

២. សកម្មភាពក្រុមប្រឹក្សារាជធានីភ្នំពេញ...

៣. សកម្មភាពអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ...

៤. សកម្មភាពអភិបាល នៃគណៈអភិបាលខណ្ឌ...

៥. ចំណេះដឹង ការកម្សាន្ត និងបទវិចារណកថាផ្សេងៗ...

ការិយាល័យនិពន្ធ

សាលារាជធានីភ្នំពេញ #៦៩, មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ៧២២ ០៥៤, ទូរសារ : (៨៥៥) ២៣ ៧២២ ០៥៤
Email: info@phnompenh.gov.kh, Website: www.phnompenh.gov.kh

សូមព្រះបារមីព្រះមហាស្វេតច្ឆត្រ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក
ប្រោសប្រទានពរជ័យ សិរីមង្គលជូន

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន
ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងឱកាសខួបកំណើតគម្រប់ ៨២ឆ្នាំ ឈានចូល ៨៣ឆ្នាំ

សូម សម្តេចចក្រី ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ
អាយុយឺនយូរដើម្បីដឹកនាំកសាង និងអភិវឌ្ឍមាតុភូមិកម្ពុជាឲ្យកាន់តែថ្កុំថ្កើនថែមទៀត។
សូម សម្តេចចក្រី និងលោកជំទាវ ព្រមទាំង បុត្រាបុត្រី ចៅៗ
ជួបតែនឹងសុភមង្គល វិបុលសុខ គ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

គោរពជូនពរពី

ខ្ញុំបាទ ប៉ា សុជាតិវង្ស និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទ
នៃសាលារាជធានីភ្នំពេញ

សូមគោរពជូនពរ និងអបអរសាទរយ៉ាងស្មោះ
អស់ពីដួងចិត្តចំពោះ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃខួបកំណើត ៦៥ឆ្នាំ ឈានចូល៦៦ឆ្នាំ

សូម សម្តេចតេជោ ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ
អាយុយឺនយូរដើម្បីដឹកនាំកសាង និងអភិវឌ្ឍមាតុភូមិកម្ពុជាឲ្យកាន់តែថ្កុំថ្កើងថែមទៀត។
សូម សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំង បុត្រាបុត្រី ចៅៗ
ជួបតែនឹងសុភមង្គល វិបុលសុខ គ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

គោរពជូនពរពី

ខ្ញុំបាទ ប៉ា សុជាតិវង្ស និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទ
នៃសាលារាជធានីភ្នំពេញ

ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលថ្មី និងចំណតក្រោមដីរបស់សាលារាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញ ពិតជាមានកិត្តិយសដ៏ធំធេងដោយទទួលបានការអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលថ្មី និងចំណតក្រោមដីរបស់សាលារាជធានីភ្នំពេញ។

យើងទាំងអស់គ្នា សូមចងចាំការណែនាំរបស់ **សម្តេចតេជោ "អគារល្អក៏ពិតមែន ប៉ុន្តែប្រសិទ្ធភាពការងារក៏ត្រូវតែខ្លាំងដែរ"**។ អគាររដ្ឋបាលសាលារាជធានីភ្នំពេញ ដែលត្រូវសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនេះ ជាសំណង់អគារប្រវត្តិសាស្ត្រមួយរបស់សាលារាជធានីភ្នំពេញ ក្នុងអាណត្តិទី៥ នៃរដ្ឋសភា បានសាងសង់ឡើងមានកម្ពស់១២ជាន់កន្លះ មានចំណតរថយន្តក្រោមដីអាចចតរថយន្តបាន ២០០គ្រឿង ដោយចំណាយពេលសាងសង់ជាងមួយឆ្នាំទើបរួចរាល់ជាស្ថាពរកាលពីខែមករា ឆ្នាំ២០១៦ ជាគំនិតច្នៃប្រឌិតរបស់ស្ថាបត្យករ និងវិស្វករខ្មែរ ដោយប្រើប្រាស់កញ្ចប់ថវិកាគុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

អគារថ្មីនេះបំពាក់សម្ភារៈការិយាល័យគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធក្រៅអគារ ពិសេសចំណតរថយន្តក្រោមដី ដែលអាចឱ្យរថយន្តចូលចតបាន ជាង២០០គ្រឿង ដើម្បីកាត់បន្ថយនូវការកកស្ទះចរាចរណ៍ និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈផងដែរ។

នេះក៏ជាសំណង់អគាររដ្ឋបាលឯកភាពមួយរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលបានបង្កនូវលក្ខណៈងាយស្រួលសម្រាប់បងប្អូនមន្ត្រីបំពេញការងារបម្រើសេវាជូនបងប្អូនប្រជាពលរដ្ឋបានឆាប់រហ័ស និងទាន់ពេលវេលា មានលក្ខណៈធំទូលាយ និងប្រមូលផ្តុំគ្រប់ទីចាត់ការគ្រប់ការិយាល័យជំនាញ គឺនៅក្នុងអគារតែមួយ។

សមិទ្ធផលដ៏ស្រស់ប្រណិតមួយនេះក៏បានបង្ហាញឱ្យឃើញពីការខិតខំប្រឹងប្រែងរបស់គណៈអភិបាល ក្រុមប្រឹក្សារាជធានីភ្នំពេញ មន្ត្រីរាជការ អាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចក្នុងការរួមចំណែកធ្វើឱ្យប្រសើរក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងរាជធានីភ្នំពេញ និងបង្កលក្ខណៈគ្រប់គ្រាន់ក្នុងការអភិវឌ្ឍរាជធានីភ្នំពេញឱ្យកាន់តែប្រសើរ និងស្រស់បំព្រងទាក់ទាញភ្ញៀវទេសចរណ៍ឱ្យកាន់តែច្រើនឡើងថែមទៀត៕



ពិធីក្រុងពាលី ឡើងអគាររដ្ឋបាលថ្មី ដែលទើបសាងសង់រួច តាមបែបសាសនា





សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញចូលរួមជាអធិបតីភាព នៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវអគាររដ្ឋបាលសាលារាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦។

នាវេសៀលថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ មានការរៀបចំពិធីក្រុងពាលី ឡើងអគាររដ្ឋបាលថ្មី ដែលទើបសាងសង់រួច តាមបែបសាសនា ដើម្បីសុំម្ចាស់ទឹក ម្ចាស់ដី អ្នកថែរក្សា និងបារមីវត្ថុស័ក្តិសិទ្ធិទាំងឡាយ សុំឱ្យជួយបីបាច់ថែរក្សា មន្ត្រីរាជការ បងប្អូនប្រជាពលរដ្ឋអាជ្ញាធរ កងកម្លាំងសមត្ថកិច្ចគ្រប់ផ្នែកឱ្យជួបតែសេចក្តីសុខ។ ពិធីក្រុងពាលីនេះ មានអញ្ជើញជាអធិបតី **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** និង **ឯកឧត្តម ម៉េង សារិន ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ** និងមន្ត្រីរាជការជាច្រើនរូបទៀត។

អគាររដ្ឋបាលសាលារាជធានីភ្នំពេញថ្មីនេះ សាងសង់រួចរាល់ជាស្ថាពរ ដោយចំណាយពេលជាងមួយឆ្នាំ និងសាងសង់ឡើងមានកម្ពស់ ១២ជាន់កន្លះ និងមានការបំពាក់សម្ភារៈការិយាល័យគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធក្រៅអគារ ពិសេសចំណតរថយន្តក្រោមដី ដែលអាចឱ្យរថយន្តចូលចតបាន ជាង២០០គ្រឿង ដើម្បីកាត់បន្ថយនូវការកកស្ទះចរាចរណ៍ និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈផងដែរ៕







ពិធីសូត្រមន្ត សុំសេចក្តីសុខសេចក្តីចម្រើនក្នុងឆ្នាំថ្មី ឆ្នាំវក អដ្ឋស័ក ពុទ្ធស័ករាជ ២៥៦០ គ.ស២០១៦







នាសៀលថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំពិធីសូត្រមន្ត ដើម្បីសុំសេចក្តីសុខសេចក្តីចម្រើននៅក្នុងឱកាសឆ្នាំថ្មី ឆ្នាំវក អដ្ឋស័ក ពុទ្ធស័ករាជ ២៥៦០ គ.ស២០១៦។

ក្នុងនាមរដ្ឋបាលរាជធានីភ្នំពេញទាំងមូល **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បានជូនពរដល់ប្រជាពលរដ្ឋទាំងអស់ក្នុងរាជធានីភ្នំពេញ ឱ្យរកស៊ីមានបាន ទទួលបានសុភមង្គលគ្រប់ក្រុមគ្រួសារ ជាពិសេសរាល់ការធ្វើដំណើរទាំងទីជិត ទាំងទីឆ្ងាយ សមប្រកបដោយសុខសុវត្ថិភាព។

ហើយយើងក៏មិនភ្លេចដែរ បងប្អូនកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលមានកាតព្វកិច្ចលំបាកជាងគេទាំងថ្ងៃបុណ្យក៏ត្រូវបំពេញតួនាទីបម្រើបងប្អូនប្រជាពលរដ្ឋ ប៉ុន្តែបងប្អូនត្រូវមានមោទនភាពថា យើងកំពុងលះបង់ដើម្បីសេចក្តីសុខជូនប្រជាពលរដ្ឋរបស់យើង។ រដ្ឋបាលរាជធានីទាំងមូល សូមជូនពរកងកម្លាំងគ្រប់លំដាប់ថ្នាក់ជួបតែសុខភាពល្អ សំណាងល្អ សុភមង្គលគ្រប់ៗគ្នា។

សូមបញ្ជាក់ផងដែរថា ជារៀងរាល់ឆ្នាំ រដ្ឋបាលរាជធានីភ្នំពេញតែងតែបានរៀបចំពិធីសូត្រមន្ត ដើម្បីសុំសេចក្តីសុខសេចក្តីចម្រើនក្នុងឆ្នាំថ្មី ដោយមានការចូលរួមយ៉ាងច្រើនកុះករពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ៕







ពិធីអបអរសាទរ ទទួលទេវតាឆ្នាំថ្មី ព្រះនាមមណ្ឌាទេវី ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០









នៅយប់ម៉ោង ៨:០០នាទី ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ នៅមេណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ និង **លោកជំទាវ** ឯកឧត្តម **ម៉ម់ សារិន** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ និង **លោកជំទាវ** ព្រមទាំងមន្ត្រីរាជការក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ បងប្អូនប្រជាពលរដ្ឋយ៉ាងច្រើនកុះករ បានប្រារព្ធពិធីអបអរសាទរ ទទួលទេវតាឆ្នាំថ្មី ព្រះនាមមណ្ឌាទេវី ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០ នៅព្រះវិហារវត្តភ្នំ នៃរមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ ដែលជានិមិត្តរូប នៃការកកើតរាជធានីភ្នំពេញ ដោយមានការបាញ់កាំជ្រួចអបអរសាទរ ទទួលទេវតាឆ្នាំថ្មី។

ក្នុងនាមរដ្ឋបាលរាជធានីភ្នំពេញទាំងមូល **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បានជូនពរដល់បងប្អូនប្រជាពលរដ្ឋទាំងអស់រកស៊ីមានបាន សុភមង្គលគ្រប់ក្រុមគ្រួសារ ជាពិសេសការធ្វើដំណើរទាំងទីជិត ទាំងទីឆ្ងាយ សមប្រកបដោយសុខសុវត្ថិភាព។

សូមបញ្ជាក់ផងដែរ ជារៀងរាល់ឆ្នាំ រដ្ឋបាលរាជធានីភ្នំពេញ តែងតែបានរៀបចំពិធីសូត្រមន្ត ដើម្បីសុំសេចក្តីសុខសេចក្តីចម្រើន ក្នុងឆ្នាំថ្មី ដោយមានការចូលរួមយ៉ាងច្រើនកុះករពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ៕



កិច្ចប្រជុំគណៈអភិបាលរាជធានីភ្នំពេញ បន្តដោះស្រាយបញ្ហា និងបម្រើការងារជូនប្រជាពលរដ្ឋ

បន្ទាប់ពីពិធីអបអរសាទរ ទទួលទេវតាឆ្នាំថ្មី "ព្រះនាមមណ្ឌាទេវី" ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០ បានបញ្ចប់ រដ្ឋបាលរាជធានីភ្នំពេញនៅមានបញ្ហាជាច្រើនដែលត្រូវបន្តដោះស្រាយ និងបម្រើជូនបងប្អូនប្រជាពលរដ្ឋ។

ជាក់ស្តែង នារសៀលថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំកិច្ចប្រជុំគណៈអភិបាលរាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ដើម្បីពិភាក្សាលើកិច្ចការសំខាន់ៗ ចំនួន ២ចំណុចដូចខាងក្រោម៖

១-ពិនិត្យ និងពង្រឹងរាល់កិច្ចការកសាង ស្ថាបនា គ្រប់គ្រងសំណង់ និងហេដ្ឋារចនាសម្ព័ន្ធនានាឱ្យបានច្បាស់លាស់។

២-កំណត់ពេលវេលានៃការផ្តល់សេវាសាធារណៈលើសេវាសុរិយោដី និងសំណង់នៅក្នុងរាជធានីភ្នំពេញឱ្យបានច្បាស់លាស់ជូនបងប្អូនប្រជាពលរដ្ឋ ព្រោះសេវានេះពិតជាមានបញ្ហាលំបាករបស់បងប្អូនទាំងការងារលក់ផ្តាច់ ការផ្ទេរបន្ត ការបំបែកលក់ ឬការសុំសាងសង់ជាដើម។

រដ្ឋបាលរាជធានីភ្នំពេញខិតខំធ្វើយ៉ាងណា បម្រើសេវាជូនបងប្អូនឱ្យកាន់តែប្រសើរឡើង កាត់បន្ថយនូវការលំបាករបស់បងប្អូនជាបន្តបន្ទាប់៕

រដ្ឋបាលរាជធានីភ្នំពេញ បានបញ្ជាទិញរថយន្តសម្អាត និងលាងធូលី-ដីតាមផ្លូវ

នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ រថយន្តបោស និងលាងផ្លូវមួយគ្រឿងបានបញ្ជូនមកដល់សាលារាជធានីភ្នំពេញហើយ ដើម្បីសម្អាតធូលី-ដី និងសម្រាប់លើកសម្រស់ទីក្រុងភ្នំពេញបន្ថែមទៀត។

គួរបញ្ជាក់ផងដែរថា រដ្ឋបាលរាជធានីភ្នំពេញ បានបញ្ជាទិញរថយន្តសម្អាត និងលាងធូលី-ដីតាមផ្លូវនេះចំនួន ២គ្រឿង និងរថយន្តបាញ់លាងការ៉ុឡាចំនួន ១គ្រឿង ហើយនៅដើមខែមេសានឹងបញ្ជូនមកគ្រប់ទាំងអស់។ ប៉ុន្តែទោះជាមានរថយន្តលាងសម្អាតយ៉ាងនេះក្តី យើងក៏នៅតែត្រូវការការចូលរួមថែរក្សាសម្រស់រាជធានីភ្នំពេញ ពីសំណាក់បងប្អូនគ្រប់ៗរូប។ ម្នាក់បេះទុកដាក់សំរាម១ ម្នាក់បានរើសសំរាម១ តើមានសំរាមមកពីណាទៀត បើយើងគ្រប់គ្នាបេះទុកដាក់ និងថែរក្សាបរិស្ថានហើយនោះ? ដូច្នេះសូមចាប់ផ្តើមពីយើងម្នាក់ៗជាមុនសិន!

នៅតំបន់មួយចំនួន ទាំងផ្លូវតូច និងផ្លូវធំ នៅក្នុងរយៈពេលចុងក្រោយនេះ សំរាមហាក់ដូចជាបានក្លាយជាវិបត្តិឡើងវិញហើយនៅរាជធានីភ្នំពេញ។ បើទោះបីជាកម្មករក្រុមហ៊ុនស៊ីនទ្រី បានប្រមូលសំរាមទាំងយប់ទាំងថ្ងៃយ៉ាងណាក៏ដោយ ក៏សំរាមនៅតំបន់មួយចំនួន រប៉ាត់រប៉ាយ និងកន្លែងខ្លះគរនៅចិញ្ចើមផ្លូវ និងហៀរដល់ទ្រូងផ្លូវក៏មាន។

ច្រើនឆ្នាំកន្លងមក ស្លឹកចេក ឬក៏ស្លឹកឈូកត្រូវបានបងប្អូនប្រជាជនខ្មែរយកមកប្រើប្រាស់ដើម្បីខ្ចប់ម្ហូបអាហារ និងរបស់សម្ភារៈប្រើប្រាស់ផ្សេងៗ។ ក៏ប៉ុន្តែ សព្វថ្ងៃនេះយើងឃើញថា ប្រជាពលរដ្ឋនិយមប្រើថង់ប្លាស្ទិកមកជំនួសវិញ ដែលជាហេតុបង្កផលប៉ះពាល់ដល់បរិស្ថាន និងសុខភាពរបស់បងប្អូនប្រជាពលរដ្ឋ។ បច្ចុប្បន្នប្រទេសកម្ពុជាសម្បូរទៅដោយសំរាម ដែលភាគច្រើនជាថង់ប្លាស្ទិក។

ប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើងចាប់ផ្តើមព្រួយបារម្ភអំពីផលប៉ះពាល់ នៃថង់ប្លាស្ទិកមកលើសុខភាពរបស់ខ្លួន និងបរិស្ថាន ប៉ុន្តែ វាត្រូវការពេលវេលាយូរដើម្បីដោះស្រាយបញ្ហានេះ៕

កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារសិក្សាគម្រោងពង្រឹងសេវារថយន្តក្រុងរបស់JICA

ការដឹកជញ្ជូនសាធារណៈ ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍ ក៏ដូចជាជួយសម្រួលដល់សណ្តាប់ធ្នាប់ចរាចរណ៍ក្នុងរាជធានីភ្នំពេញផងដែរ។

រសៀលថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញដឹកនាំដោយ**ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បានជួបពិភាក្សាជាមួយក្រុមការងារសិក្សាគម្រោងពង្រឹងសេវារថយន្តក្រុងរបស់JICA ហើយរដ្ឋបាលរាជធានីភ្នំពេញយើងសូមឯកភាពនូវចំណុចមួយចំនួនដូចខាងក្រោម៖

១-ការផ្តល់រថយន្តក្រុងឱ្យដាក់ដំណើរការជាដំហានៗ ដើម្បីការប្រើប្រាស់ ការគ្រប់គ្រង និងនិរន្តរភាពនៃដំណើរការនេះ។

២-ខិតខំដោះស្រាយបញ្ហាចំណត រៀបចំរោងជាង និងទីតាំងធ្វើការងារឱ្យបានត្រឹមត្រូវ។

៣-គិតគូរយកចិត្តទុកដាក់អំពីប្រាក់បៀវត្សរបស់បុគ្គលិក និងអ្នកបើកបរ ដើម្បីឱ្យឆ្លើយតបទៅនឹងគោលនយោបាយលក្ខន្តិកៈរដ្ឋាករស្វយ័តរថយន្តក្រុងសាធារណៈដែលទើបបង្កើត។

ជាការឆ្លើយតបរបស់ក្រុមសិក្សា JICA បានបញ្ជាក់ថា JICA នឹងផ្តល់រថយន្តក្រុងដែលជាជំនួយឥតសំណងមករាជធានីភ្នំពេញជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៧ ដើម្បីបន្តដំណើរការឱ្យបានចំនួន ១០ ខ្សែរត់។

ក្នុងនោះដែរ JICA ក៏សំណូមពរឱ្យរដ្ឋបាលរាជធានីភ្នំពេញត្រៀមជ្រើសរើសអ្នកបើកបររថយន្ត និងអ្នកហែកសំបុត្រជាច្រើននាក់បន្ថែមទៀតផង។ ជាចុងក្រោយរដ្ឋបាលរាជធានីភ្នំពេញ បានធ្វើការចុះហត្ថលេខាលើកំណត់ហេតុពិភាក្សាស្តីពីការសិក្សាអង្កេតបឋមដំណាក់កាលទី២ សម្រាប់គម្រោងពង្រឹងសមត្ថភាពសេវាដឹកជញ្ជូនសាធារណៈដោយរថយន្តក្រុង នៅក្នុងរាជធានីភ្នំពេញជាមួយJICA ផងដែរ៕

កិច្ចប្រជុំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កំណត់បែងចែកភារកិច្ចមន្ត្រីក្រោមឱវាទរដ្ឋាករស្វយ័តរថយន្តក្រុង

នាព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បានប្រជុំពិភាក្សាលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កំណត់បែងចែកភារកិច្ចមន្ត្រីក្រោមឱវាទរដ្ឋាករស្វយ័តរថយន្តក្រុងដឹកជញ្ជូនសាធារណៈ ដើម្បីពង្រឹងប្រសិទ្ធភាពលើការគ្រប់គ្រង និងផ្តល់សេវារថយន្តក្រុងឱ្យកាន់តែប្រសើរជូនដល់បងប្អូនប្រជាពលរដ្ឋយើង។

សូមបញ្ជាក់ដែរថា កន្លងមករដ្ឋាភិបាលជប៉ុនតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) គ្រោងនឹងផ្តល់រថយន្តក្រុងចំនួន ១៨០គ្រឿង ដែលជំនួយឥតសំណងរបស់រដ្ឋាភិបាល និងប្រជាជនជប៉ុនដល់កម្ពុជា ដើម្បីពង្រឹងសមត្ថភាពសេវាដឹកជញ្ជូនសាធារណៈ និងដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ដែលកើតមានឡើងនៅក្នុងរាជធានីភ្នំពេញ។ JICA ប្រកាសបែបនេះ ក្នុងពិធីចុះហត្ថលេខាលើកំណត់ហេតុពិភាក្សា ស្តីពីការសិក្សាអង្កេតបឋមសម្រាប់គម្រោងពង្រឹងសមត្ថភាពសេវាដឹកជញ្ជូនសាធារណៈ តាមរយៈរថយន្តក្រុងជាមួយអាជ្ញាធរសាលារាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦។

បើតាមផែនការឆ្នាំ២០១៦ របស់សាលារាជធានីភ្នំពេញ សាលារាជធានីភ្នំពេញនឹងដំណើរការប្រព័ន្ធឆូតកាតអេឡិចត្រូនិចនៅពេលឡើងជិះរថយន្តផងដែរ ដើម្បីកាត់បន្ថយចំនួនបុគ្គលិក និងទូទាត់ថ្លៃមិនយកសេវាធ្វើដំណើរពីសិស្ស ព្រះសង្ឃ ជនពិការ និងចាស់ជរា។ តាមការវាយតម្លៃពីប៉ះពាល់ជាបឋមរបស់អ្នកជំនាញបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញបាននាំឱ្យខាតបង់ថវិកាជាង ៦លានដុល្លារក្នុងមួយខែៗ។ បច្ចុប្បន្ន សេវារថយន្តក្រុងសាធារណៈនៅរាជធានីភ្នំពេញមានចំនួន ៣ខ្សែ ក្នុងនោះ ខ្សែរត់ទី១ ចេញពីម្តុំតំបន់ឬស្សីកែវ ត្រង់គីឡូម៉ែត្រលេខ៩ ឆ្ពោះទៅដល់ក្តីតាកុយ តាមផ្លូវជាតិលេខ១ ខ្សែទី២ ពីផ្សាររាត្រីទៅដល់ក្រុងតាខ្មៅ និងខ្សែទី៣ ចេញពីផ្សារចាស់ឆ្ពោះទៅដល់រង្វង់មូលចោមចៅ៕



ប្រតិភូរដ្ឋបាលរាជធានីភ្នំពេញជួបប្រជុំពិភាក្សាជាមួយប្រតិភូក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីផ្តល់សេវាសាធារណៈលើកិច្ចការសាធារណការ និងដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ

បន្ទាប់ពីបានជួបពិភាក្សាដោះស្រាយការងារសេវាសុរិយោដី ជូនបងប្អូនប្រជាពលរដ្ឋរួចមក នារសៀលថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បានជួបជាមួយ **ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន** និងសហការី ដើម្បីពិភាក្សាការងារផ្តល់សេវាសាធារណៈលើកិច្ចការសាធារណការ និងដឹកជញ្ជូនក្នុងរាជធានីភ្នំពេញឱ្យកាន់តែប្រសើរ។

ជាលទ្ធផលនៃកិច្ចជំនួបនេះ បានទទួលនូវការឯកភាព និងសម្រេចបាននូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១-រៀបចំដាក់ម៉ាស៊ីនបោះពុម្ពកាតបើកបរដោយផ្ទាល់នៅផ្សារទំនើបអ៊ីអនម៉ល សម្រាប់បងប្អូនដែលត្រូវប្តូរប័ណ្ណបើកបរថ្មី នាពេលឆាប់ៗខាងមុខ ដើម្បីសម្រេចឱ្យបាននូវផែនការ១០០ថ្ងៃ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

២-កាត់បន្ថយនូវពេលវេលាផ្តល់សេវាសាធារណៈជូនដល់បងប្អូនប្រជាពលរដ្ឋ ដូចជាការធ្វើប័ណ្ណបើកបរ ការលក់ផ្តាច់ ការត្រួតពិនិត្យឈៀក ឬការធ្វើស្លាកលេខជាដើម។ ម្យ៉ាងទៀត នឹងផ្លាស់ប្តូរកិច្ចការមួយចំនួន ឱ្យទៅជាប្រព័ន្ធបច្ចេកវិទ្យាទំនើប(ប្រព័ន្ធគ្រប់គ្រងតាមIT)៕

៣-គូសគំនូសចរាចរណ៍ថ្មីលើផ្លូវចំនួន ៥ខ្សែ ដូចជាមហាវិថីម៉ៅសេទុង មហាវិថីព្រះសីហនុ មហាវិថីនរោត្តម មហាវិថីសហព័ន្ធរុស្ស៊ី និង មហាវិថីកម្ពុជាក្រោម (មហាវិថីម៉ៅសេទុង និងព្រះសីហនុ គឺជាជំនួយរបស់ក្រុមហ៊ុនចិន ហើយក្រៅពីនោះជាបន្ទុកចំណាយរបស់រដ្ឋបាលរាជធានីភ្នំពេញ)។

៤-យកចិត្តទុកដាក់ និងទប់ស្កាត់ការដឹកជញ្ជូនលើសទម្ងន់ ដែលជាមូលហេតុបណ្តាលឱ្យមានការខូចខាតផ្លូវជាខ្លាំង។

៥-សិក្សាកែប្រែចំណុចប្រសព្វផ្លូវរង្វង់មូលមួយចំនួន ទៅជាភ្លើងស្តុប និងកំណត់ផ្លូវឯកទិសនៅតាមផ្លូវសំខាន់ៗមួយចំនួន ដើម្បីកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍ជូនបងប្អូន៕





ធុងសំរាមចល័តចំនួន ២២៦ធុង នឹងដាក់ពង្រាយទៅតាមទីសួនសាធារណៈ និងតាមទីផ្សារនានា







ធុងសំរាមចល័តចំនួន ២២៦ធុង (មានកង់ ១០៣ធុង និងអត់កង់ ១២៣ធុង) នឹងដាក់ពង្រាយទៅតាមទីសួនសាធារណៈ និងតាមទីផ្សារនានា ដើម្បីលើកស្ទួយសោភណភាព និងថែរក្សាបរិស្ថានទីក្រុងរបស់យើង។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បានលើកទឹកចិត្តដល់ក្រុមភ្នាក់ងារសំរាមរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលនឹងត្រូវបែងចែកគ្នាទៅតាមគោលដៅសំខាន់ៗ ហើយ **ឯកឧត្តមអភិបាល** សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋនឹងចូលរួមថែរក្សាទាំងអស់គ្នា ព្រោះបរិស្ថានស្អាតទាល់តែមានការចូលរួមពីបងប្អូនគ្រប់ៗគ្នា។

រយៈពេល៦ឆ្នាំចុងក្រោយនេះ សំរាមនៅក្នុងរាជធានីភ្នំពេញជាង៣លានតោន ត្រូវបានចាក់នៅទីលានចាក់សំរាមខណ្ឌដង្កោ ហើយក្នុងឆ្នាំ២០១៥ សំរាមជាមធ្យមប្រមាណ២ពាន់តោនត្រូវបានដឹកយកមកចាក់នៅទីលានជារៀងរាល់ថ្ងៃ ដែលមានសមាសធាតុដូចជា៖ ៥៧.៤%ជាសំរាមម្ហូបអាហារ ១៨.១%ជាថង់ប្លាស្ទីក ៦%ជាក្រដាស ០.២%ជាកៅស៊ូ និងស្បែក និង១៨.៣%ជាស្មៅ ឈើ ដែក ក្រណាត់ ថ្មផ្សេងៗ(ការសិក្សារបស់ ASIA Foundation/ITC)។

ដោយសារទីតាំងចាក់សំរាមចាស់មិនអាចទទួលសំរាមបន្ត រដ្ឋបាលរាជធានីភ្នំពេញបានសិក្សាទីតាំងថ្មីចំនួនពីរបន្ថែមទៀត នៅក្បែរនោះដើម្បីចាក់សំរាមបន្ត។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមអភិបាល** បានឧបត្ថម្ភការសាងសង់អគារស្នាក់នៅមួយខ្នងសម្រាប់បុគ្គលិកនៃទីលានចំនួន៣៤នាក់ ដែលបំពេញការងារ ២៤/២៤ម៉ោង ៧ថ្ងៃ/សប្តាហ៍ ចែកចេញជា២វេនធ្វើការ។

សូមគូសបញ្ជាក់ផងដែរថា បច្ចុប្បន្ននេះ រដ្ឋបាលរាជធានីភ្នំពេញមានទីលានចាក់សំរាមដង្កោតែមួយប៉ុណ្ណោះ ដែលមានទំហំផ្ទៃក្រឡាជាង៣១ហិកតា ដែលជាជំហានបន្តបន្ទាប់រដ្ឋបាលរាជធានីភ្នំពេញនឹងសិក្សារកទីតាំង២កន្លែងផ្សេងទៀត ដែលស្ថិតក្នុងខណ្ឌជ្រោយចង្វារ និងខណ្ឌច្បារអំពៅ ក្នុងគោលបំណងទប់ស្កាត់ការនាំយកសំរាមមកពីទីឆ្ងាយជាហេតុបណ្តាលឱ្យមានភាពយឺតយាវ និងបណ្តាលឲ្យកកស្ទះចរាចរណ៍ ឬមានគ្រោះថ្នាក់ចរាចរណ៍ផ្សេងៗ។ បន្ទាប់ពីពិនិត្យទីលានចាក់សំរាមរួច **ឯកឧត្តមអភិបាល** បានបន្តទៅពិនិត្យទីតាំងរបស់ក្រុមហ៊ុនស៊ិនទ្រី។

នៅតំបន់មួយចំនួន ទាំងផ្លូវតូច និងផ្លូវធំ នៅក្នុងរយៈពេលចុងក្រោយនេះ សំរាមហាក់ដូចជាបានក្លាយជាវិបត្តិឡើងវិញហើយនៅរាជធានីភ្នំពេញ។ បើទោះបីជាកម្មករក្រុមហ៊ុនស៊ីនទ្រី បានប្រមូលសំរាមទាំងយប់ទាំងថ្ងៃយ៉ាងណាក៏ដោយ ក៏សំរាមនៅតំបន់មួយចំនួន រប៉ាត់រប៉ាយ និងកន្លែងខ្លះ គរនៅចិញ្ចើមផ្លូវ និងហៀរដល់ទ្រូងផ្លូវក៏មាន។

មានហេតុផលច្រើនយ៉ាង ដែលនាំឱ្យកើតមានគំនរសំរាមរាយប៉ាយនៅក្នុងរាជធានីភ្នំពេញ គឺបណ្តាលមកពីបងប្អូនប្រជាពលរដ្ឋទុកដាក់សំរាមវេចខ្ចប់មិនមានសណ្តាប់ធ្នាប់ និងមិនមានធុងសំរាមត្រឹមត្រូវ ហើយម្យ៉ាងវិញទៀតមកពីក្រុមហ៊ុនស៊ិនទ្រី ដែលម៉ៅការខាងប្រមូលសំរាម មិនសូវបានយកសំរាមទៀងទាត់។ ដូច្នេះ ដើម្បីដោះស្រាយវិបត្តិសំរាមនៅក្នុងរាជធានីភ្នំពេញ ប្រជាពលរដ្ឋគួរតែទុកដាក់វេចខ្ចប់សំរាមឱ្យបានត្រឹមត្រូវ ហើយគួរមានធុងសំរាម នៅមុខផ្ទះរបស់ខ្លួន។

ចំណែកក្រុមហ៊ុនស៊ិនទ្រី ត្រូវចាត់កម្លាំងប្រមូលសំរាមនៅតាមផ្ទះប្រជាពលរដ្ឋឱ្យបានទៀងទាត់ មួយថ្ងៃម្តងជាប្រចាំ។ ចំណែកអាជ្ញាធរសមត្ថកិច្ចវិញ ក៏ត្រូវតែដាក់វិធានការចុះពិនិត្យតាមដាន និងរឹតបន្តឹងក្រុមហ៊ុនស៊ិនទ្រី គឺត្រូវតែដាក់កម្លាំងចុះប្រមូលសំរាមឱ្យទៀងទាត់។ ប្រសិនបើក្រុមហ៊ុនស៊ិនទ្រី មិនមានលទ្ធភាពប្រមូលសំរាមឱ្យទៀងទាត់ទេ អាជ្ញាធរភូមិ សង្កាត់ គួរចាត់កម្លាំងរបស់ខ្លួនដើម្បីប្រមូលសំរាម ហើយយកលុយថ្លៃសេវាប្រមូលសំរាម ជំនួសក្រុមហ៊ុនស៊ិនទ្រីតែម្តង៕

រដ្ឋបាលរាជធានីភ្នំពេញ មានគម្រោងបង្កើតរោងចក្រកែច្នៃសំរាម

ប្រតិភូរដ្ឋបាលរាជធានីភ្នំពេញចុះពិនិត្យ និងដោះស្រាយបញ្ហាប្រឈមមួយចំនួន ក្នុងរាជធានីភ្នំពេញ

នារសៀលថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បាន ដឹកនាំមន្ត្រីក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ និងមន្ត្រីជំនាញ មន្ទីរពាក់ព័ន្ធនានា ចុះពិនិត្យ និងដោះស្រាយការងារសំខាន់ៗ បីចំណុច នៅក្នុងមូលដ្ឋានផ្ទាល់ដូចខាងក្រោម៖



១-ពិនិត្យ និងជំរុញការរៀបចំតភ្ជាប់ផ្លូវក្រោយសណ្ឋាគារភ្នំពេញ កាត់តាមព្រះវិហារឥស្លាម ចេញមកផ្លូវក្នុងតំបន់បឹងកក់ (ផ្លូវ R4)។

២-ពិនិត្យ និងជំរុញការស្ថាបនាស្ថានីយ៍បូមទឹកទួលគោក២ ឱ្យបានរួចរាល់មុនរដូវវស្សាខាងមុខនេះ។ គួរបញ្ជាក់ថា ស្ថានីយ៍ថ្មីនេះស្ថាបនាបាន ៨០%ហើយ មានសមត្ថភាពបូមទឹករហូតដល់ ៥ ម៉ែត្រគីបក្នុងមួយវិនាទី លើសពីម៉ាស៊ីនចាស់ ៣ដង ហើយជាកន្លែងបញ្ចេញទឹកពីតំបន់ផ្សារដេប៉ូ តំបន់៧មករា កម្ពុជាក្រោមជាដើម។

៣-ពិនិត្យ និងជំរុញការតភ្ជាប់ផ្លូវR9 និងផ្លូវR10 ដែលជាផ្លូវរំដោះចរាចរណ៍ពីតំបន់ទួលគោកទៅជ្រោយចង្វារ ឬកាល់ម៉ែត្រ។

កន្លងមកមន្ត្រីជំនាញខាងផ្នែកប្រព័ន្ធលូទឹកបានឱ្យដឹងថា អាជ្ញាធររាជធានីភ្នំពេញនៅមិនទាន់អាចដោះស្រាយបញ្ហាលិចលង់ដោយទឹកភ្លៀងនៅក្នុងតំបន់មួយចំនួនបានទាំងស្រុងនៅឡើយទេ ដោយសារការអភិវឌ្ឍ ដែលបានប៉ះពាល់ដល់ប្រព័ន្ធ បង្ហូរទឹក ហើយការលិចលង់នោះបាននាំឱ្យប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងនោះសម្តែងសេចក្តីខឹងសម្បារ ព្រោះពួកគាត់ពិបាកក្នុងការរស់នៅ ការប្រកបរបររកស៊ី និងការធ្វើដំណើរទៅមក។

កន្លងមកនៅក្នុងរាជធានីភ្នំពេញ តែងជួបបញ្ហាប្រឈមជាញឹកញាប់ជាមួយទឹកលិចផ្លូវ និងលំនៅដ្ឋានបងប្អូនប្រជាពលរដ្ឋពេលដែលមានភ្លៀងធ្លាក់ខ្លាំង ស្របពេលអាជ្ញាធរមូលដ្ឋានបានប្រឹងប្រែងបូមទឹកចេញពីកន្លែងលិចយ៉ាងញាប់ដៃញាប់ជើង ដោយប្រើម៉ាស៊ីនបូមទឹកច្រើនគ្រឿង ប៉ុន្តែនៅតែមិនអាចកាត់បន្ថយការជន់លិចទាន់ពេលវេលា។ បន្ថែមលើបញ្ហាទាំងនេះ កន្លងមកអាជ្ញាធររាជធានីភ្នំពេញ បានខិតខំប្រឹងប្រែងសិក្សា និងស្ដាបនាផ្លាស់ប្ដូរប្រព័ន្ធលូពីតូចទៅធំជាច្រើនកន្លែងផងដែរ ប៉ុន្តែទឹកនៅតែលិចដោយសារធ្លាក់ភ្លៀងគំហុកខ្លាំង ប្រព័ន្ធលូហូរទឹកមិនទាន់។

ប្រជាពលរដ្ឋនឹងបានសប្បាយចិត្ត បន្ទាប់ពីផ្លូវទាំងនេះ និងស្ថានីយ៍បូមទឹកថ្មីរបស់យើងដាក់ដំណើរការជាស្ថាពរ ហើយបញ្ហាការកកស្ទះចរាចរណ៍ និងទឹកលិចជុំវិញតំបន់បឹងកក់នឹងត្រូវកាត់បន្ថយ បានប្រសើរនាពេលឆាប់ៗខាងមុខនេះ៕









ពិធីតែងតាំងមុខតំណែងអភិបាលខណ្ឌសែនសុខថ្មី គឺ លោក ម៉ឺល គុសល ជំនួស លោក លី សាទេត

នាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំពិធីប្រកាសតែងតាំងមុខតំណែងអភិបាលខណ្ឌសែនសុខថ្មី គឺ **លោក ម៉ឺល គុសល** ជំនួស **លោក លី សាទេត** ដែលត្រូវបានទៅកាន់តំណែងថ្មី ជាអភិបាលរងខេត្តកំពត ក្រោមអធិបតីភាព







ឯកឧត្តម ម៉ប់ សារិន ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ និង **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**។

ក្នុងពិធីនេះដែរ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ក៏បានផ្តាំផ្ញើនូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

១-ត្រូវធ្វើការងារដោយយកចិត្តទុកដាក់កុំបន្សល់ឱ្យមានបញ្ហាដល់ថ្នាក់ក្រោមរបស់យើង។

២-ត្រូវថែរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋឱ្យបានល្អទប់ស្កាត់នូវរាល់អំពើចោរកម្ម លួច ប្លន់ គ្រោះអគ្គីភ័យ ចរាចរណ៍ ល្បែងស៊ីសង គ្រឿងញៀនគ្រប់ប្រភេទ និងរឿងការគ្រប់គ្រងសំណង់ សុរិយោដីផងដែរ។

៣-បង្កើនសមត្ថភាពបម្រើការងារជូនបងប្អូនប្រជាពលរដ្ឋ ឱ្យបានលឿនទាន់ពេលវេលា។

៤-សេវាសាធារណៈត្រូវធ្វើឱ្យបានលឿន និងមានគណនេយ្យភាពដើម្បីតម្រូវការរបស់ប្រជាពលរដ្ឋរបស់យើង ជាពិសេសត្រូវត្រួតពិនិត្យ និង ជួសជុលឡើងវិញនូវផ្លូវដែលខូចខាត និងប្រឡាយប្រព័ន្ធលូគ្រប់កន្លែង ដោយយកចិត្តទុកដាក់ខ្ពស់នៅក្នុងខណ្ឌរបស់ខ្លួន៕



ពិធីចែកមួកសុវត្ថិភាពចំនួន១.000មួកជូនដល់យុវជនកាកបាទក្រហមកម្ពុជា និងសិស្សានុសិស្ស

នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ សាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិកគណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា** និង**ជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ** បានអញ្ជើញជាអធិបតីក្នុងពិធីចែកមួកសុវត្ថិភាពចំនួន១.០០០មួក របស់ក្រុមហ៊ុន យូនីលីវើ (ខេមបូឌា) លីមីធីត ជូនដល់យុវជនកាកបាទក្រហមកម្ពុជា និងសិស្សានុសិស្ស មកពី ២៣សាលាក្នុងរាជធានីភ្នំពេញ ដែលពិធីនេះ ធ្វើឡើងនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ។

ក្នុងឱកាសនោះដែរ **ឯកឧត្តមប្រធានគណៈកម្មាធិការសាខា** បានមានប្រសាសន៍ថ្លែងអំណរគុណដល់ក្រុមហ៊ុន យូនីលីវើ (ខេមបូឌា) លីមីធីត ដែលបានជួយឧបត្ថម្ភនូវមួកសុវត្ថិភាព ស្របពេលដែលរាជរដ្ឋាភិបាល បាននឹងកំពុងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ដើម្បីជាការរួមចំណែកជាមួយការងារមនុស្សធម៌របស់សាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ ក្នុងការធ្វើយុទ្ធនាការផ្សព្វផ្សាយសុវត្ថិភាពចរាចរណ៍ ក្នុងរាជធានីភ្នំពេញ ឱ្យកាន់តែប្រសើរ និងទទួលបានផ្លែផ្កាជាវិជ្ជមាន៕

ពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារថ្មី វត្តព្រែកឯង ស្ថិតនៅសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ

នាព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ៨៖០០នាទី **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាល នៃគណៈអភិបាលរាជធានី**ភ្នំពេញ** បានអញ្ជើញជាអធិបតី ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារថ្មី វត្តព្រែកឯង ស្ថិតនៅសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



ព្រះពុទ្ធសាសនារបស់យើងមានអាយុកាល ២៥៦០ឆ្នាំ ហើយមកដល់ពេលនេះ ប៉ុន្តែព្រះពុទ្ធសាសនាសម្រាប់កម្ពុជាទើបតែចាប់ផ្តើមឡើងវិញ៣៧ឆ្នាំនេះ ព្រោះសាសនារបស់យើងត្រូវបំផ្លាញដោយពួកប៉ុលពតនៅក្នុងរបបប្រល័យពូជសាសន៍ បានកម្ទេចវត្តអារាម និងបំបាត់មិនឱ្យមានព្រះសង្ឃ។

ចាប់ពីឆ្នាំ១៩៧៩មកដល់ពេលបច្ចុប្បន្ននេះ មានរយៈពេល ៣៧ឆ្នាំហើយ វិស័យព្រះពុទ្ធសាសនាមានការរីកចម្រើនខ្លាំងឡើងវិញ ដោយសារតែប្រទេសយើងទទួលបាននូវសុខសន្តិភាព។

ក្នុងឱកាសនោះដែរ **ឯកឧត្តមអភិបាល** បានសំណូមពរដល់ព្រះចៅអធិការវត្តនូវ ២ចំណុច៖

-ទី១៖ សូមឱ្យមានការសិក្សាពីបទដ្ឋានប្លង់វិហារឱ្យបានត្រឹមត្រូវតាមបច្ចេកទេសសាងសង់ដើម្បីឱ្យបានអាយុកាលយូរអង្វែង

-ទី២៖ ត្រូវមានគណៈកម្មការមួយរៀបចំយន្តការដឹកនាំប្រមូលធនធានបច្ច័យឱ្យបានច្បាស់លាស់។

ក្នុងនោះផងដែរ **ឯកឧត្តមអភិបាល** បាននាំយកអំណោយរដ្ឋបាលរាជធានីភ្នំពេញ ដែលមានដូចជា៖

-ឧបត្ថម្ភសិស្សកាយរិទ្ធ ចំនួន៥០នាក់ ក្នុងម្នាក់ៗទទួលបានថវិកាចំនួន១០.០០០រៀល

-ឧបត្ថម្ភយុវជនកាកបាទក្រហម ចំនួន៥០នាក់ ក្នុងម្នាក់ៗទទួលបានថវិកាចំនួន ១០.០០០៛

-ឧបត្ថម្ភ អនុវិទ្យាល័យព្រែកឯង ថវិកាចំនួន ១.០០០.០០០រៀល

-ឧបត្ថម្ភ វិទ្យាល័យព្រែកឯង ថវិកា ចំនួន ១.០០០.០០០រៀល៕

កិច្ចប្រជុំផ្សព្វផ្សាយ សមាសភាពក្រុមការងារចម្រុះចុះអនុវត្តផែនការ ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រសួងមហាផ្ទៃ

នាព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តម ឃួង ស្រេង** អភិបាលរងរាជធានីភ្នំពេញ និង ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃុន សំបូរ** អគ្គនាយករងអន្តោប្រវេសន៍ និងជាប្រធានក្រុមការងារចម្រុះ ចុះអនុវត្តការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ខណ្ឌ **ចំការមន** បានបើកកិច្ចប្រជុំបន្ទាន់មួយអំពីការផ្សព្វផ្សាយសមាសភាពក្រុមការងារចម្រុះចុះអនុវត្តផែនការ ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន្តក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រសួងមហាផ្ទៃ។

នៅក្នុងការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍នេះ វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សេដ្ឋកិច្ច សន្តិសុខ និងសិទ្ធិមនុស្ស ក្នុងកិច្ចប្រជុំនោះផងដែរ **ឯកឧត្តម ឃួង ស្រេង** បានផ្តល់ជាអនុសាសន៍ថា ត្រូវធ្វើឱ្យបានល្អ ម៉ត់ចត់ ច្បាស់លាស់ ច្បាប់គឺច្បាប់ ដើម្បីឱ្យប្រទេសយើងមានការគ្រប់គ្រងល្អដូចអរិយប្រទេសក្នុងពិភពលោកផងដែរ។

សូមគូសបញ្ជាក់ផងដែរថា សម្រាប់ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន្តនេះធ្វើឡើងក្នុងខណ្ឌចំនួន៨ នៅក្នុងរាជធានីភ្នំពេញ ដែលខណ្ឌ៤ និងខេត្តផ្សេងៗទៀត បានស្រង់នូវស្ថិតិជនបរទេសរួចអស់ហើយ៕

កិច្ចប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំធនាគារពិភពលោកអំពីលទ្ធផលនៃបេសកកម្មនៅសៀមរាប និង ពិភាក្សាបន្តក្នុងការរៀបចំគម្រោងអនុវត្តនៅក្នុងរាជធានីភ្នំពេញ

នាល្ងាចថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តម អៀង អូនលី អភិបាលរងរាជធានីភ្នំពេញ** បានជួបពិភាក្សាជាមួយថ្នាក់ដឹកនាំធនាគារពិភពលោកអំពីលទ្ធផលនៃបេសកកម្មនៅសៀមរាប និង ពិភាក្សាបន្តក្នុងការរៀបចំគម្រោងអនុវត្តនៅក្នុងរាជធានីភ្នំពេញផងដែរ។

ក្នុងឱកាសនោះដែរ **ឯកឧត្តម អៀង អូនលី អភិបាលរងរាជធានីភ្នំពេញ** បានមានប្រសាសន៍ថា ក្រោមស្មារតីនៃកិច្ចប្រជុំ ដើម្បីឱ្យការអភិវឌ្ឍន៍មានភាពជាដៃគូយូរអង្វែង គឺយើងត្រូវតែសហការគ្នាឱ្យបានល្អទាំងការសិក្សាដំបូង និងសម្រេចជាឯកសារគោលដែលត្រូវចងក្រង ដើម្បីប្រើប្រាស់ជាដំណាក់ៗ រួមទាំងថ្ងៃអនាគត នៅពេលដែលអនុវត្តដើម្បីឱ្យការសម្រេចបាននូវជាស្ថិតិរួមគ្នាមួយដ៏ជាក់លាក់ផងដែរ។ កន្លងមករដ្ឋបាលរាជធានីភ្នំពេញតែងស្វាគមន៍ និងសហការជាមួយក្រុមហ៊ុន អង្គការ និងស្ថាប័ននានា ដែលមានបំណងចូលរួមជួយអភិវឌ្ឍន៍ និងដោះស្រាយរាល់បញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងរាជធានីភ្នំពេញ៕

ពិធីប្រារព្ធទិវាសុខភាពពិភពលោក ឆ្នាំ២០១៦ ក្រោមប្រធានបទ "ជំងឺទឹកនោមផ្អែម"

នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តម ម៉ុន សេរី អភិបាលរងរាជធានីភ្នំពេញ** បានអញ្ជើញជាគណៈអធិបតីក្នុងការប្រារព្ធទិវាសុខភាពពិភពលោក ឆ្នាំ២០១៦ ក្រោមប្រធានបទ **"ជំងឺទឹកនោមផ្អែម"** ដើម្បីបង្កើនការយល់ដឹងអំពីទឹកនោមផ្អែម ការព្យាបាល ការថែទាំ និងការធ្វើរោគវិនិច្ឆ័យដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅបរិវេណទីលានប្រជាធិបតេយ្យ ដែលមានអ្នកចូលរួមប្រមាណជាង ៣០០នាក់។

ជាការពិតណាស់ជំងឺទឹកនោមផ្អែម គឺជាជំងឺមួយប្រភេទដែលតែងតែគំរាមកំហែងអាយុជីវិតអ្នកជំងឺគ្រប់ពេលវេលាទាំងអស់ ជាពិសេស នៅពេលដែលលោកអ្នកមិនបានអនុវត្តទៅតាមការណែនាំរបស់គ្រូពេទ្យឯកទេសនោះ ។

ជំងឺទឹកនោមផ្អែមជាជំងឺមួយប្រភេទក្នុងបណ្តាជំងឺជាច្រើននាបច្ចុប្បន្នដែលត្រូវការព្យាបាលដោយការប្រើថ្នាំ រួមជាមួយនឹងការតម្រូវឱ្យអ្នកជំងឺអនុវត្តការបរិភោគ និងដំណើរជីវិតតាមបទបញ្ជារបស់គ្រូពេទ្យផងដែរ។ ក្រៅអំពីការផ្តល់ថ្នាំព្យាបាល គ្រូពេទ្យនឹងណែនាំដល់អ្នកជំងឺឱ្យផ្លាស់ប្តូរវិធីរស់នៅប្រចាំថ្ងៃ ដើម្បីឱ្យដំណើរការព្យាបាលទទួលបានជោគជ័យ។ ហើយវិធានការនៃការផ្លាស់ប្តូរសកម្មភាពរស់នៅប្រចាំថ្ងៃមានដូចជា បង្រៀនឱ្យគេយល់ដឹងអំពីលក្ខណៈនៃជំងឺ ការបរិភោគអាហារ និងការហាត់ប្រាណ៕

ពិធីចាប់ឆ្នោតយកដីឡូតិ៍ជាមួយប្រជាពលរដ្ឋនៅភូមិ១ សង្កាត់ស្រះចក តាមបណ្តោយផ្លូវរថភ្លើង

នៅព្រឹកថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំពិធីចាប់ឆ្នោតយកដីឡូតិ៍ជាមួយប្រជាពលរដ្ឋនៅភូមិ១ សង្កាត់ស្រះចក តាមបណ្តោយផ្លូវរថភ្លើង ១៦គ្រួសារ (ក្រុមចាន់ ពុទ្ធិស័ក) និងប្រជាពលរដ្ឋសេសសល់នៅតំបន់បឹងកក់ ០៦គ្រួសារ ក្រោមការដឹកនាំផ្ទាល់ **លោក មាន ចាន់យ៉ាដា នាយករដ្ឋបាលរាជធានីភ្នំពេញ** និង **លោក គួច ចំរើន អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ**។

ក្នុងឱកាសនោះ **លោក មាន ចាន់យ៉ាដា** បានលើកឡើងថា លទ្ធផលជោគជ័យនៅក្នុងថ្ងៃនេះ កើតចេញពីការខិតខំយកចិត្តទុកដាក់ដោះស្រាយរបស់រដ្ឋបាលរាជធានីភ្នំពេញ ក្រោមការដឹកនាំ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ជាពិសេសតាមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ដោយឈរលើការយោគយល់ ស្មោះត្រង់ជាមួយគ្នា តម្លាភាព និងយុត្តិធម៌យ៉ាងពិតប្រាកដ៕

អាជ្ញាធររាជធានីភ្នំពេញ ចុះពិនិត្យ និងរុះរើផ្ទាំងប៉ាណូផ្សាយពាណិជ្ជកម្មគ្មានសណ្តាប់ធ្នាប់

ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ធ្លាប់មានប្រសាសន៍ថា ផ្ទាំងប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មបច្ចុប្បន្នគឺ កើតមានច្រើនពេកហើយក្នុងរាជធានីភ្នំពេញ សាលារាជធានីភ្នំពេញនឹងកាត់បន្ថយផ្ទាំងផ្សាយពាណិជ្ជកម្មនេះ ឱ្យនៅកម្រិតមួយសមស្រប មិនឱ្យប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់ទីក្រុង។

ចុះពិនិត្យទីតាំងស្នើសុំរបស់ក្រុមហ៊ុនសុំតម្លើងផ្ទាំងផ្សព្វផ្សាយ

ក្រោយពីបានទទួលគោលការណ៍ណែនាំផ្ទាល់ពី **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ក្រុមការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសទីតាំងផ្ទាំងផ្សាយពាណិជ្ជកម្ម តែងតែបានចុះពិនិត្យ និងរុះរើផ្ទាល់នូវគោមភ្លើង ប្រអប់ភ្លើង LED ផ្ទាំងផ្សាយពាណិជ្ជកម្មណាដែលបានសាងសង់ដោយមិនមានច្បាប់អនុញ្ញាត និងបង្កឱ្យមានផលប៉ះពាល់ដល់គំហើញ សោភ័ណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងរាជធានីភ្នំពេញ។

ក្រុមការងាររបស់សាលារាជធានីភ្នំពេញ តែងបានសហការជាមួយសាលាខណ្ឌទាំង១២ ចុះពិនិត្យ និងរុះរើគោមភ្លើង ប្រអប់ភ្លើង និងផ្ទាំងផ្សាយពាណិជ្ជកម្មជាច្រើនទីតាំង ដាក់លើចិញ្ចើមផ្លូវថ្មើរជើង ដែលបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ តាមដងវិថីនានា។

ក្រោយពីបានអនុវត្តវិធានការរដ្ឋបាលបានមួយជំហានរួចមក យើងសង្កេតឃើញថា នៅតាមបណ្តោយផ្លូវមួយចំនួនក្នុងរាជធានីភ្នំពេញមានសណ្តាប់ធ្នាប់ និងសោភ័ណភាពប្រសើរឡើងវិញ ហើយបងប្អូនប្រជាពលរដ្ឋមានការគាំទ្រចំពោះចំណាត់ការនេះ ព្រមទាំងបានស្ម័គ្រចិត្តរុះរើគោមភ្លើង ប្រអប់ភ្លើង និងផ្ទាំងផ្សាយដោយខ្លួនឯង ហើយជាពិសេសថែមទៀតនោះ គឺបណ្តាក្រុមហ៊ុនដែលជាប្រភពផ្គត់ផ្គង់សំខាន់ៗ ក៏បានចុះកាត់គោមភ្លើង ប្រអប់ភ្លើង និងផ្ទាំងផ្សាយពាណិជ្ជកម្មដោយខ្លួនឯងដែរ។ ទន្ទឹមនេះ ក្រុមការងារបានសំណូមពរដល់ក្រុមហ៊ុនឱ្យបញ្ឈប់ការផ្គត់ផ្គង់សម្ភារៈផ្សព្វផ្សាយ ដែលនាំឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពរាជធានីភ្នំពេញ៕

ប្រជុំពង្រឹងសុវត្ថិភាពការដ្ឋាន ស្លាកសញ្ញាចរាចរណ៍

នាព្រឹកថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បានបើកកិច្ចប្រជុំក្រុមហ៊ុនស្ថាបនាផ្លូវ លូ ស្ថានីយ៍បូមទឹក សំដៅពង្រឹងសុវត្ថិភាពការដ្ឋាន ស្លាកសញ្ញាការដ្ឋាន គុណភាពនៃការសាងសង់សំណង់ បទដ្ឋានបច្ចេកទេស ដោះស្រាយនូវរាល់ផលប៉ះពាល់ និងជំរឿនលទ្ធផលការងារការដ្ឋាន។

អង្គភាពស្ពានថ្នល់ និងការិយាល័យសាធារណការ ត្រូវចាត់មន្ត្រីជាវិស្វករចុះតាមដានការងារគ្រប់ការដ្ឋាន និងចុះជួសជុលគ្រលុកសំបុកមាន់ក្នុងរាជធានីភ្នំពេញចំនួន ៦ក្រុម។ ក្រុមការងារត្រូវបន្តជួយសម្រួលចរាចរណ៍ផ្លូវកប់ស្រូវ និងចុះជួសជុលបន្ទាន់ផ្លូវលេខ១១០ ព្រែកប្រា ចាប់ពីពេលនេះតទៅ។

រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំកែលម្អប្រព័ន្ធចរាចរណ៍

នាយប់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំកែលម្អប្រព័ន្ធចរាចរណ៍សាកល្បងតំបន់រង្វង់មូលទួលគោក ដោយតម្លើងបេតុងទ្រូងផ្លូវវិថីសម្តេច ប៉ែន នុត ឬផ្លូវលេខ ២៨៩ ប្រវែង ៤៥២ម ចាប់ពីរង្វង់មូលទួលគោកដល់ភ្លើងស្តុបប្រសព្វរវាងវិថីសម្តេច ប៉ែន នុត និងផ្លូវលេខ ៥៦៦។

ការកែលម្អប្រព័ន្ធចរាចរណ៍សាកល្បងនេះ នឹងបិទរង្វង់មូលទួលគោកមិនអោយធ្វើចរាចរណ៍វិលជុំដូចមុនឡើយ ហើយការធ្វើចរាចរណ៍ពីស្ពានអាកាស៥មករាមកដល់រង្វង់មូលនេះ នឹងមិនអនុញ្ញាតឱ្យបត់ឆ្វេងមកផ្លូវលេខ៥៩២ និងផ្លូវលេខ២៦០៨ដូចមុនឡើយ ប៉ុន្តែការធ្វើចរាចរណ៍អាចទៅត្រង់ដោយបត់ឆ្វេងនៅចំណុចភ្លើងស្តុបប្រសព្វរវាងវិថីសម្តេច ប៉ែន នុត និងផ្លូវលេខ៥៦៦។





ខណ្ឌដង្កោ

រដ្ឋបាលខណ្ឌដង្កោចុះពិនិត្យមើលស្ថានភាពស្រូវប្រាំង និងចុះចែកទឹកជូនប្រជាពលរដ្ឋ

នាព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ លោក **នុត ពុធដារ៉ា អភិបាល នៃគណៈអភិបាលខណ្ឌដង្កោ** បានដឹកនាំមន្ត្រីរាជការសាលាខណ្ឌ សង្កាត់ ចុះពិនិត្យមើលស្ថានភាពស្រូវប្រាំងរបស់បងប្អូនប្រជាពលរដ្ឋក្នុងភូមិចំនួន ០៤ ស្ថិតនៅក្នុងសង្កាត់ប្រទះឡាង ដែលក្នុងនោះរួមមាន៖ ភូមិអង្គ ភូមិភា ភូមិតាំងរនាម និងភូមិប្រទះឡាង ព្រមទាំងបានចុះពិនិត្យការបូមទឹកសង្គ្រោះស្រូវទាំងនោះ លើផ្ទៃដីស្រែប្រមាណ៨០ហិកតា។

ក្នុងឱកាសនោះ **លោកអភិបាលខណ្ឌ** ក៏បានឧបត្ថម្ភនូវប្រេងម៉ាស៊ូតចំនួន ៥០០លីត្រ សម្រាប់ប្រើប្រាស់ក្នុងការបូមទឹកនេះ ហើយបន្ថែមពីនេះទៀត **លោក ម៉ៅ ប៊ុនធឿន** ប្រធានមន្ទីរធនធានទឹក ក៏បានឧបត្ថម្ភប្រេងម៉ាស៊ូត ៥០០លីត្រផងដែរ៕

អនុវត្តតាមប្រសាសន៍ណែនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងឆ្លើយតបទៅនឹងតម្រូវការចាំបាច់ប្រចាំថ្ងៃ ដែលកំពុងជួបការខ្វះខាតទឹកប្រើប្រាស់ក្នុងរដូវប្រាំងនាពេលបច្ចុប្បន្ន របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ **លោក នុត ពុធដារ៉ា អភិបាល នៃគណៈអភិបាលខណ្ឌដង្កោ** និង **លោក ប្រាជ្ញ សីហា អភិបាលរងខណ្ឌដង្កោ** បានដឹកនាំមន្ត្រីរាជការក្រោមឱវាទ និងក្រុមយុវជន ស.ស.យ.ក ខណ្ឌដង្កោ ដឹកទឹកចុះចែកជូនប្រជាពលរដ្ឋតាមខ្នងផ្ទះ ចំនួន ២ភូមិ រួមមាន ភូមិខ្វិត និងភូមិក្រាំងតាផូ ស្ថិតនៅសង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ព្រមជាមួយគ្នានោះ **លោកអភិបាល** ក៏បានបន្តដំណើរទៅសួរសុខទុក្ខ និងត្រួតពិនិត្យប្រព័ន្ធផ្គត់ផ្គង់ទឹករបស់បងប្អូនប្រជាពលរដ្ឋរស់នៅសហគមន៍ទួលសំបូរ ដែលជាអំណោយរបស់ **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ស្ថិតក្នុងសង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ៕

ខណ្ឌសែនសុខ

អនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌសែនសុខ ចុះសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារប្រើប្រាស់ជូនគ្រួសារក្រីក្រ

នាព្រឹកថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ **លោក ប៊ឹស កុសល ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌសែនសុខ** និង លោក **ថេង សុផុល** ប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌសែនសុខ បានដឹកនាំក្រុមការងារសាខាចុះសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារប្រើប្រាស់មួយចំនួនរបស់ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ទៅចែកជូនប្រជាពលរដ្ឋក្រីក្រចាស់ជរាចំនួន ៥៣គ្រួសារ ស្ថិតនៅសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ដោយក្នុងមួយគ្រួសារទទួលបានអង្ករចំនួន ៣០គីឡូក្រាម មីចំនួន ០១កេស ត្រីខចំនួន ១០កំប៉ុង ឃីត(សារុង ក្រមា មុង ភួយ) ចំនួន ០១ឈុត និងបានឧបត្ថម្ភថវិកាក្នុងមួយគ្រួសារទទួលបានចំនួន ២០.០០០រៀល ក្នុងនោះសប្បុរសជន **លោក ពៅ ណារិទ្ធ អនុប្រធានកិត្តិយសអនុសាខា** បានចូលរួមឧបត្ថម្ភក្នុងមួយគ្រួសារទទួលថវិកា ១០.០០០រៀល៕

ក្រុមការងារចុះពិនិត្យ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសាងសង់សំណង់នានា នៅក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងរណបជ្រោយចង្វារ ស្ថិតក្នុងខណ្ឌជ្រោយចង្វារ

ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ នារសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ បានដឹកនាំក្រុមការងារចុះពិនិត្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសាងសង់សំណង់នានា នៅក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងរណប

ជ្រោយចង្វារ ស្ថិតក្នុងខណ្ឌជ្រោយចង្វារ ដែលទទួលបានលទ្ធផលដូចជា៖

-ជំរុញឱ្យក្រុមហ៊ុនសាងសង់ឱ្យបានលឿន ការសាងសង់អគាររដ្ឋបាលខណ្ឌជ្រោយចង្វារឱ្យបានឆាប់ ដើម្បីឱ្យមន្ត្រីសាលាខណ្ឌអាចចូលបម្រើការងារជូនប្រជាពលរដ្ឋ។ ជាមួយគ្នានោះផងដែរ **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ក៏បានថ្លែងកោតសរសើរចំពោះក្រុមហ៊ុន OCIC សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយភាពទទួលខុសត្រូវខ្ពស់ ជាមួយនឹងការដាក់បណ្តាញលូបង្ហូរទឹកយ៉ាងត្រឹមត្រូវ និងតែងតែយកចិត្តទុកដាក់ដោះស្រាយបញ្ហាផលប៉ះពាល់ជាមួយបងប្អូនប្រជាពលរដ្ឋ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

-បានចុះពិនិត្យការដ្ឋានសាងសង់ផ្លូវ ស្របតាមផ្លូវជាតិ៦A ពីអ័ក្សផ្លូវ១០០ម៉ែត្រ ប្រវែងប្រមាណ ៦គីឡូម៉ែត្រ គិតចាប់ពីវិថីសម្តេចជា ស៊ីម សង្កាត់ព្រែកលៀប មកដល់រង្វង់មូលជ្រោយចង្វារត្រើយខាងកើត។ ក្នុងឱកាសនោះដែរ **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ក៏បានចុះពិនិត្យមើលទីតាំងសាងសង់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងបានពិនិត្យមើលការសាងសង់អគាររដ្ឋបាលខណ្ឌជ្រោយចង្វារ ព្រមទាំងពិនិត្យមើលការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់អភិវឌ្ឍន៍ជ្រោយចង្វារ ដែលស្ថិតនៅខណ្ឌជ្រោយចង្វាររបស់ក្រុមហ៊ុន OCIC ផងដែរ។

-អំពាវនាវដល់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ សូមកុំព្រួយបារម្ភចំពោះការអភិវឌ្ឍន៍នេះ រដ្ឋបាលរាជធានីភ្នំពេញ នឹងបន្តដោះស្រាយការងារនេះ ដោយមិនឱ្យបងប្អូនប្រជាពលរដ្ឋខាតបង់នោះឡើយ គឺមានតែចំណេញ៕

អនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌច្បារអំពៅ ចុះសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារប្រើប្រាស់ជូនគ្រួសារក្រីក្រ

នាព្រឹកថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ **លោក អ៊ាង ស៊ីផាន** អភិបាល នៃគណៈអភិបាលខណ្ឌច្បារអំពៅ និងជាប្រធានអនុសាខាកាកបាទក្រហមខណ្ឌច្បារអំពៅ លោក **អ៊ុំ ម៉ារ៉េត** ប្រធានក្រុមប្រឹក្សាខណ្ឌច្បារអំពៅ លោក លោកស្រី អភិបាលរងខណ្ឌ រួមដំណើរ

ដោយមន្ត្រីក្រោមឱវាទខណ្ឌ សង្កាត់ យុវជនកាកបាទក្រហមកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា(សសយក) បានចុះសួរសុខទុក្ខ និងពាំនាំយកអំណោយរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ចែកជូនដល់បងប្អូនជួបការខ្វះខាតជីវភាពចំនួន ៧០គ្រួសារ ដែលរស់នៅក្នុងសហគមន៍វាលស្បូវ ក្នុងសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះ **លោកអភិបាលខណ្ឌ** ក៏បានប្រគល់បន្ថែមនូវអណ្តូងស្នប់ចំនួន២ សម្រាប់បងប្អូនប្រើប្រាស់ក្នុងសហគមន៍ និងបានចែកជូនកង់ចំនួន ៣០គ្រឿងដល់ក្មួយៗសិស្សានុសិស្សសម្រាប់ជាមធ្យោបាយធ្វើដំណើរទៅសាលារៀនដែលនៅឆ្ងាយ រួមនឹងថវិកាមួយចំនួនផងដែរ។

ខណ្ឌ៧មករា

រដ្ឋបាលខណ្ឌ៧មករាបានដឹកនាំក្រុមការងារចុះត្រួតពិនិត្យគម្រោងអភិវឌ្ឍក្នុងមូលដ្ឋានខណ្ឌ

នារសៀលថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦ **លោក លឹម សុវត្ថា អភិបាល នៃគណៈអភិបាលខណ្ឌ៧មករា** បានដឹកនាំក្រុមការងារចុះត្រួតពិនិត្យគម្រោងអភិវឌ្ឍខណ្ឌ៧មករា។

សម្រាប់ឆ្នាំ២០១៥ សម្រេចបាន 100% ដែលក្នុងនោះមាន៖

១. គម្រោងជួសជុលផ្ទៃផតស្រុតដោយចាក់អ៊ុតកៅស៊ូបេតុងបេទីមីណឺ (AC) លើកំណាត់ផ្លូវចំនួន ៣ខ្សែ គឺផ្លូវលេខ ១១៥,២១១ និងផ្លូវលេខ ១៤១ ដែលមានប្រវែង ៤.៩៣៣ម៉ែត្រ។

២. គម្រោងជួសជុលដាក់ប្រព័ន្ធលូថ្មីចំនួន ២ខ្សែ មានប្រវែង ១.៥២០ម៉ែត្រគឺ លូមុខកាត់ 0.៦ម៉ែត្រ ផ្លូវលេខ ១៦១, ២១១, ១៦៩, ១៦៤ និងលូមុខកាត់ 0,៨ម៉ែត្រ ផ្លូវលេខ ១៨២, ២១៥, ១២៥។

៣. គម្រោងស្តារប្រព័ន្ធលូមានប្រវែងចំនួន ៦.៤៥៨ម៉ែត្រ និងជួសជុលអណ្តូងលូចំនួន ៨0ដូចជា៖

- ស្តារប្រព័ន្ធលូមុខកាត់ 0.៨ម៉ែត្រ ផ្លូវលេខ១៦៩ ប្រវែង ៨២៥ម៉ែត្រ។
- ស្តារប្រព័ន្ធលូមុខកាត់ 0.៦ម៉ែត្រ ផ្លូវលេខ ១0៥, ១១៨, ១៤៣ ប្រវែង ៥.៦៣៣ម៉ែត្រ។
- ជួសជុលអណ្តូងលូចំនួន ៨0អណ្តូង ផ្លូវលេខ ១0៥, ១១៣, ១២៥, ១៤៣, ១៦៩។

៤. គម្រោងជួសជុលថែទាំលើកំណាត់ផ្លូវលេខ ១0៩,១៣៩,១៤៣ ផ្ទៃក្រឡាសរុប ៤៩១ម៉ែត្រការ៉េ។

៥. គម្រោងដាក់ភ្លើងបំភ្លឺផ្លូវសាលាខណ្ឌ (ផ្លូវលេខ៣៣៦ និងផ្លូវលេខតាមខឿងហែមភូមិ ១-៥ ក្នុងសង្កាត់ទាំង៧) ចំនួន ៩១អំពូល។

៦. គម្រោងជួសជុលជណ្តើររួមក្នុងសង្កាត់អូរឫស្សីទី២ មួយកន្លែង។

គម្រោងសម្រាប់ឆ្នាំ២០១៦ មានរាយនាមដូចខាងក្រោម៖

១. ជួសជុលអ៊ុតកៅស៊ូ (AC) លើកំណាត់ផ្លូវលេខ ១១៨ និងផ្លូវលេខ ១២៥ ដែលមានផ្ទៃក្រឡាសរុប ៦.៧០៣ម៉ែត្រការ៉េ។

២. ជួសជុលសំបុកកំណាត់ផ្លូវលេខ ១៨២, ២១៣, ១៥៦, ១៥0, ១៣៤, ១២៨, ២០៨, ៩៣, ២១៧, ១៦៩ និងផ្លូវភូមិ១២បុរីកីឡា ក្នុងសង្កាត់វាលវង់ មានផ្ទៃក្រឡាសរុប ២.0៩៥ម៉ែត្រការ៉េ។

៣. ជួសជុលដាក់ប្រព័ន្ធលូទំហំ 0,៨ម៉ែត្រ លើកំណាត់ផ្លូវលេខ ២១៣ និងផ្លូវលេខ ២០៦ ដែលមានប្រវែងសរុប ៥៤៧ម៉ែត្រ។

៤. ជួសជុលអណ្តូងលូលើកំណាត់ផ្លូវចំនួន ៦ខ្សែមាន ១៨0អណ្តូង។

៥. ស្តារលូចំនួន ៤ខ្សែ មានប្រវែង ៦.៩៣0ម៉ែត្រ មុខកាត់0,៦ម៉ែត្រ។

៦. គម្រោងដាក់ភ្លើងបំភ្លឺផ្លូវក្នុងសង្កាត់ទាំង៨ ចំនួន ១២៣អំពូល។

៧. គម្រោងជួសជុលជណ្តើរក្នុងសង្កាត់មិត្តភាព និងសង្កាត់មនោរម្យ៕

ខណ្ឌពោធិ៍សែនជ័យ

រដ្ឋបាលខណ្ឌពោធិ៍សែនជ័យរៀបចំកម្មវិធីពោធិ៍សែនជ័យសង្ក្រាន្ត ក្នុងបរិវេណវត្តកិត្តិប្បញ្ញោ

នារសៀលថ្ងៃទី ៨ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តម ហ៊ុន ម៉ានី** តំណាងរាស្ត្រខេត្តកំពង់ស្ពឺ និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា ឯកឧត្តម **ស សុខា** តំណាងរាស្ត្រខេត្តព្រៃវែង និង **ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ចូលរួមក្នុងកម្មវិធីពោធិ៍សែនជ័យសង្ក្រាន្ត ដែលបានរៀបចំដោយរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ ស្ថិតក្នុងបរិវេណវត្តកិត្តិប្បញ្ញោ សង្កាត់សំរោងក្រោម។

ព្រឹត្តិការណ៍ពោធិ៍សែនជ័យសង្ក្រាន្ត គឺជាព្រឹត្តិការណ៍លើកទី១ ដែលបានរៀបចំឡើងនៅក្នុងខណ្ឌពោធិ៍សែនជ័យ ដែលពីមុនមកមិនធ្លាប់មានព្រឹត្តិការណ៍នេះទេ។

កម្មវិធីសង្ក្រាន្តដ៏មានអត្ថន័យនេះ មានការផ្តួចផ្តើមឡើងដោយ ឯកឧត្តម **គ្រួច ផាន** ប្រធានក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ និង លោក **ហែម ដារិទ្ធិ** អភិបាល នៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ ព្រមទាំងមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់មន្ត្រីក្រោមឱវាទគ្រប់ផ្នែក គ្រប់ជំនាញ ជាពិសេសបងប្អូនប្រជាពលរដ្ឋក្នុងខណ្ឌទាំងមូលតែម្តង។ ព្រឹត្តិការណ៍ពោធិ៍សែនជ័យសង្ក្រាន្ត ក៏បាននាំយកនូវល្បែងប្រជាប្រិយជាច្រើនប្រភេទ មុខម្ហូបខ្មែរ នំប្រពៃណី ការប្រណាំងរទេះគោលឿន និងការប្រឡងបវរស្ត្រីឯកប្រចាំខណ្ឌ ដែលមានអាយុចាប់ពី ៥៥ឆ្នាំឡើងទៅ ហើយឱកាសនោះក៏មានការតាំងពិព័រណ៍លក់ផលិតផល និងវត្ថុអនុស្សាវរីយ៍ក្នុងតម្លៃពិសេសផងដែរ។ ការប្រារព្ធព្រឹត្តិការណ៍ពោធិ៍សែនជ័យសង្ក្រាន្តនេះ បានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ គឺថ្ងៃទី ០៧-០៨-០៩ ខែមេសា ឆ្នាំ២០១៦៕

ខណ្ឌព្រែកព្នៅ

រដ្ឋបាលខណ្ឌព្រែកព្នៅ បានរៀបចំវេទិកាសាធារណៈ នៅក្នុងមូលដ្ឋានខណ្ឌព្រែកព្នៅ

នាព្រឹកថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ រដ្ឋបាលខណ្ឌព្រែកព្នៅ បានរៀបចំវេទិកាសាធារណៈស្តីពីការតាមដានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក្នុងមូលដ្ឋានសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ ក្រោមអធិបតីភាព **ឯកឧត្តម រស់ សុផាន់ ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខណ្ឌព្រែកព្នៅ** និងជារដ្ឋលេខាធិការ

ក្រសួងមុខងារសារធារណៈ លោក **សុខ សម្បត្តិ** អភិបាលនៃគណៈអភិបាលខណ្ឌព្រែកព្នៅ លោក **ម៉ៅ ម៉ូរ៉ា** ប្រធានក្រុមប្រឹក្សាខណ្ឌព្រែកព្នៅ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាខណ្ឌ លោកនាយក-នាយករង ការិ.ចំណុះជំនាញជុំវិញខណ្ឌ មន្ត្រីសាលាខណ្ឌ ចៅសង្កាត់ទាំង៤ និងបងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានចូលរួមសរុបចំនួនជាង ៣០០នាក់ផងដែរ ស្ថិតនៅក្នុងវត្តបឹងប្រិយ៍ ភូមិតាគល់ សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះផងដែរ គណៈអធិបតី បានស្នើសុំឱ្យបងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន លើកឡើងនូវរាល់បញ្ហាប្រឈម និងសំណូមពរនានាបន្ថែមដែលកើតមានឡើងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់បងប្អូនជូនវេទិកាជ្រាបច្បាស់ ដើម្បីឱ្យអាជ្ញាធរមូលដ្ឋានរដ្ឋបាលខណ្ឌ មន្ទីរ សង្កាត់ ភូមិ និងគណៈអធិបតី ជួយដោះស្រាយ ទាន់ពេលវេលា។

ក្រោយពីបានទទួលការអនុញ្ញាតពីគណៈអធិបតី បងប្អូនប្រជាពលរដ្ឋបានលើកឡើងនូវរាល់បញ្ហាប្រឈមដែលតែងជួបប្រទះនៅក្នុងមូលដ្ឋាន ហើយអាជ្ញាធរពាក់ព័ន្ធក៏បានចូលរួមដោះស្រាយបញ្ហាលំបាកទាំងនោះជូនបងប្អូនមួយចំនួនផ្ទាល់ និងសន្យាបន្តដោះស្រាយរាល់បញ្ហាដែលនៅសល់ជាមួយថ្នាក់ដឹកនាំ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីជាប្រយោជន៍ដល់បងប្អូនមូលដ្ឋានឱ្យបានទាន់ពេលវេលា៕

ក្រុមការងាររដ្ឋបាលខណ្ឌទួលគោកបានចុះរៀបចំសណ្តាប់ធ្នាប់ សោភណ្ឌភាព ក្នុងមូលដ្ឋាន

នាព្រឹកថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៦ **លោក ប៉ាង លីដា អភិបាលរងខណ្ឌទួលគោក** បានដឹកនាំក្រុមការងារចុះរៀបចំសណ្តាប់ធ្នាប់ សោភណ្ឌភាព និងរុះរើស្តង់ចាក់បេតុងលក់ងារ និងតូបលក់ដូរ នៅក្នុងតំបន់ត្រឡោកបែក ផ្លូវ៥៩៨ នៅក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ។

ការចុះរៀបចំសណ្តាប់ធ្នាប់ និងរុះរើក្នុងពេលនេះ បន្ទាប់ពីក្រុមការងារ និងអាជ្ញាធរមូលដ្ឋាន បានចុះពន្យល់ណែនាំច្រើនលើកច្រើនសារ តែម្ចាស់អាជីវកម្មនៅតែមិនស្តាប់ ដូចនេះអាជ្ញាធរមានតែប្រើវិធានការក្តៅ៕

នារៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ក្រុមការងារសាលាខណ្ឌទួលគោក ដឹកនាំដោយ **លោក ប៉ាង លីដា អភិបាលរងខណ្ឌទួលគោក** បន្តចុះរៀបចំសណ្តាប់ធ្នាប់ ផ្លូវ៥៩៨ (ត្រឡោកបែក)។

មុននឹងចុះរៀបចំសណ្តាប់ធ្នាប់ និងរុះរើក្នុងពេលនេះ បន្ទាប់ពីក្រុមការងារ និងអាជ្ញាធរមូលដ្ឋាន បានចុះពន្យល់ណែនាំច្រើនលើកច្រើនសារឱ្យម្ចាស់ផ្ទះរុះសំយ៉ាបដោយខ្លួនឯង និងបានណែនាំឱ្យបងប្អូនអាជីវករដែលលក់ដូរនៅលើចំណីផ្លូវ និងលើចិញ្ចើមផ្លូវសាធារណៈចូលទៅក្នុងបរិវេណផ្ទះ។

នៅក្នុងដំណើរការរំដោះចិញ្ចើមផ្លូវនេះ អាជ្ញាធរមូលដ្ឋាន និងក្រុមការងារខណ្ឌទួលគោក បានទទូចស្នើសុំឱ្យបងប្អូនប្រជាពលរដ្ឋ បន្តចូលរួមសហការជាមួយអាជ្ញាធរខណ្ឌ ដើម្បីលុបបំបាត់នូវការកកស្ទះចរាចរណ៍ រក្សាបាននូវសោភណ្ឌភាព និងសណ្តាប់ធ្នាប់ នៅក្នុងរាជធានីភ្នំពេញ៕

រដ្ឋបាលខណ្ឌចំការមនចុះចែកអំណោយជូនគ្រួសារក្រីក្រ និងសូត្រមន្តលើករាសីឆ្នាំថ្មីឆ្នាំវក

នាវេលាព្រឹកថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ អនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌចំការមន បានរៀបចំពិធីចែកអំណោយមនុស្សធម៌របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ជូនប្រជាពលរដ្ឋក្រីក្រចំនួន ៣៥គ្រួសារ ក្នុងសង្កាត់ផ្សារដើមថ្កូវ ក្រោមអធិបតីភាព **លោក គឹម ឈុនអ៊ូ ប្រធានអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌចំការមន** និង **លោក ព្រំ សំខាន់** ប្រធានកិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌចំការមន។

អំណោយដែលយកមកផ្តល់ជូនបងប្អូនប្រជាពលរដ្ឋក្រីក្រក្នុងឱកាសនោះ ក្នុង១គ្រួសារៗ ទទួលបានអង្ករ២៥គីឡូក្រាម ត្រីខ០១យួ មី០១កេស មុង០១ ក្រមា០១ ភួយ០១ សារុង០១ និងថវិកា ៣០.០០០រៀល។

ក្នុងឱកាសនោះ **លោក គឹម ឈុនអ៊ូ** បានសំណូមពរដល់បងប្អូនប្រជាពលរដ្ឋ ឱ្យយកចិត្តទុកដាក់ខ្ពស់ចំពោះអនាម័យ និងសុខភាពរស់នៅប្រចាំថ្ងៃរបស់សមាជិកគ្រួសារ៕

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ នៅសាលាខណ្ឌចំការមន បាននិមន្តព្រះសង្ឃសូត្រមន្តលើករាសីឆ្នាំថ្មីឆ្នាំវក អដ្ឋស័ក ពុទ្ធស័ករាជ ២៥៦០ គ.ស២០១៦ ជូនមន្ត្រីរាជការសាលាខណ្ឌចំការមន ដែលមានការអញ្ជើញចូលរួមពី **លោក ព្រំ សំខាន់ អភិបាល នៃគណៈអភិបាលខណ្ឌចំការមន លោក គឹម ឈុនអ៊ូ ប្រធានក្រុមប្រឹក្សាខណ្ឌចំការមន** គណៈអភិបាលខណ្ឌ និងមន្ត្រីសាលាខណ្ឌចំការមនទាំងអស់។

ក្នុងពិធីនេះដែរ **លោកអភិបាលខណ្ឌ** បានជូនពរដល់មន្ត្រីក្រោមឱវាទ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋឱ្យរកស៊ីមានបាន សុភមង្គលគ្រប់ក្រុមគ្រួសារ ជាពិសេសការធ្វើដំណើរទាំងទីជិត ទាំងទីឆ្ងាយសមប្រកបដោយសុខសុវត្ថិភាព និងបានឧបត្ថម្ភថវិកាជូនមន្ត្រីសាលាខណ្ឌម្នាក់ៗ ចំនួន៤០.០០០រៀល ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី៕

ចំណេះដឹងសុខភាព៖ **អត្ថប្រយោជន៍ រមៀត! និង ត្រប់វែង!**

ប្រទេសជាច្រើនដែលស្ថិតនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ និងប្រទេសឥណ្ឌាខាងត្បូង ចូលចិត្តប្រើដើមរមៀតស្រស់ដាក់នៅក្នុងម្ហូបអាហារ។ រមៀតមានជាតិហិរដូចជាខ្ញីដែរ ហើយជាឱសថដ៏មានតម្លៃដែលត្រូវបានគេនាំចេញពីប្រទេសចិនទៅកាន់ប្រទេសឥណ្ឌា។

នៅក្នុងប្រទេសលោកខាងលិច បានរកឃើញថារមៀតមានប្រសិទ្ធភាពខ្ពស់ក្នុងការជួយព្យាបាល**ជម្ងឺស្អួត**។ មិនតែប៉ុណ្ណោះរមៀត គឺជាគ្រឿងផ្សំដ៏សំខាន់មួយនៅក្នុងអាហារ និងជាឱសថដ៏សក្តិសិទ្ធសម្រាប់ព្យាបាលជម្ងឺនៅក្នុងទីក្រុងចាម៉ូនៃប្រទេសបាលី។

រមៀត មានកិត្តិនាមជាថ្នាំជ្រលក់ពណ៌ដ៏ស្រស់ស្អាតដែលធ្វើឱ្យអ្វីៗក្លាយទៅជាពណ៌លឿងភ្លឺចែងចាំង។ ពិសេសជានេះទៀត រមៀតជួយធ្វើឲ្យផ្ទៃមុខមត់រលោងផងដែរ៕

ត្រប់វែង គឺជាបន្លែមួយប្រភេទ ដែលមានសាច់ និងរសជាតិប្លែកគេ ហើយអាចរកទិញបាននៅលើទីផ្សារគ្រប់រដូវកាល។ មិនខ្វល់ថាវាមានរូបរាង ឬពណ៌បែបណានោះទេ តែត្រប់វែងទាំងអស់ សុទ្ធតែមានជីវជាតិដ៏មានប្រយោជន៍សម្រាប់សុខភាព។

បញ្ចុះកូឡេស្តេរ៉ុលក្នុងឈាម

ត្រប់វែង ផ្ទុកដោយសារធាតុ Chlorogenic Acid ដ៏ពិសេសមួយដែលត្រូវបានគេស្គាល់ថាជាអ្នកប្រឆាំង នឹងរ៉ាឌីកាល់សេរីដ៏អស្ចារ្យបំផុតក្នុងរុក្ខជាតិលើលោកនេះ។ សារធាតុមួយនេះ ក៏ត្រូវបានគេស្គាល់ទៀតថាអាចកាត់បន្ថយកូឡេស្តេរ៉ុលអាក្រក់ និងដើរតួនាទីជាថ្នាំប្រឆាំងនឹងវីរុស មហារីក និងមេរោគផ្សេងៗទៀតផងដែរ។

អាហារខួរក្បាល

សំបកត្រប់វែង មានសារធាតុ Nasunin ដែលជា Anthocyanin និងត្រូវបានគេស្គាល់ថាជាអង់ទីអុកស៊ីដង់ដ៏ខ្លាំងមួយ សម្រាប់ការពារភ្នាស់ខ្លាញ់របស់កោសិកា។

មហារីក

ត្រប់វែង មានសារធាតុ Polyphenols ដែលត្រូវបានរកឃើញថាមានប្រសិទ្ធប្រឆាំងនឹងមហារីក។ ចំពោះសារធាតុ Chlorogenic Acid និង Anthocyanin ធ្វើការប្រឆាំងនឹងការរលាក និងអង់ទីអុកស៊ីដង់។

ទឹកនោមផ្អែម

ត្រប់វែង ត្រូវប្រើប្រាស់សម្រាប់គ្រប់គ្រងជំងឺទឹកនោមផ្អែម។ ការសិក្សាជាច្រើន ក៏បានគាំទ្រលើមុខងារមួយនេះដែរ ដោយសារតែវាមានកាបូអ៊ីដ្រាតទាប និងជាតិសរសៃខ្ពស់តែម្តង។

សុខភាពបេះដូង

ត្រប់វែង មានជាតិប៉ូតាស្យូម សរសៃ វីតាមីន B6 វីតាមីន C និង Phytonutrients ដែលសុទ្ធសឹងតែជួយទ្រទ្រង់ដល់សុខភាពបេះដូងទាំងអស់។ ការញ៉ាំអាហារសម្បូរសារធាតុ Flavonoids ឃើញថា ជួយកាត់បន្ថយការកើតជំងឺបេះដូង ហើយត្រប់វែងសំបូរដោយសារធាតុនេះរួចទៅហើយ៕

ចំណេះដឹង និងកំសាន្ត៖ **ឪពុកអ្នកមាននាំកូនទៅមើលផ្ទះអ្នកក្រ អ្វីដែលកូនលើកឡើងធ្វើឱ្យឪពុកបាត់មាត់បាត់ក**

របស់សំខាន់បំផុតក្នុងជីវិតរបស់មនុស្ស...

ថ្ងៃមួយ! ឪពុកមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់បានយកកូនរបស់គាត់ធ្វើដំណើរទៅប្រទេសមួយក្នុងគោលបំណងតែមួយគត់ គឺចង់បង្ហាញឱ្យកូនគាត់មើលជាក់ស្តែង ថាតើអ្នកក្រមានសភាពបែបណា។ ហើយពួកគេបានចំណាយពេល៣-៤ថ្ងៃនៅកសិដ្ឋានរបស់គ្រួសារក្រីក្រមួយ។

បន្ទាប់ពីត្រឡប់ពីធ្វើដំណើរវិញ ឪពុកបានសួរកូនរបស់គាត់ថា តើកូនចូលចិត្តដំណើរកម្សាន្តនេះអត់?

កូនឆ្លើតបវិញថា "**ដំណើរកម្សាន្តនោះល្អខ្លាំងណាស់! ប៉ា**"។

ឪពុកសួរទៀតថា "**តើកូនបានឃើញថាតើអ្នកក្រមានសភាពបែបណា?**"

កូនឆ្លើយថា "**បាទប៉ា! ខ្ញុំបានឃើញ!**"។

ឪពុកសួរកូនទៀតថា "**អ៊ីចឹងតើកូនបានរៀនអ្វីខ្លះពីដំណើរកម្សាន្តនោះ**"?។

កូនឆ្លើយតប

- ខ្ញុំបានឃើញថា ពួកគេមានឆ្កែមួយមានជើងបួន ដូចជាឆ្កែយើងដែរ។

- យើងមានអាងហែលទឹកមួយដែលលាតសន្ធឹងនៅកណ្តាលសួនច្បារ ហើយពួកគេមានស្ទឹងឆ្ងាយដាច់កន្ទុយភ្នែកមួយ។

- យើងមានអំពូលបំភ្លឺក្នុងសួនច្បាររបស់យើង រីឯពួកគេមានតារារះនៅលើមេឃពេលយប់។

- កន្លែងអង្គុយលេងរបស់យើងស្ថិតនៅវេរ៉ង់ដា ហើយពួកគេមានជើងមេឃទាំងមូលជាកន្លែងអង្គុយលេង។

- យើងមានដីតែមួយកន្លែងប៉ុណ្ណោះដើម្បីរស់នៅ ហើយពួកគេមានវាលស្រែដែលមើលទៅដាច់កន្ទុយភ្នែក។

- យើងមានអ្នកបម្រើជាច្រើននាក់ ប៉ុន្តែពួកគេបម្រើអ្នកដទៃ។

- យើង ទិញអាហារគេទទួលទាន ប៉ុន្តែពួកគេផលិតអាហារដោយខ្លួនឯង។

- យើងមានជញ្ជាំងថ្មជុំវិញពួកយើងដើម្បីការពារ ពួកគេមានមិត្តភក្តិដើម្បីការពារពួកគេ"។

ឪពុករបស់ក្មេងនោះបានបាត់មាត់ឈឹង បន្ទាប់មកកូនគាត់បន្ថែមទៀតថា "**ទាំងនេះបង្ហាញថាយើងពិតជាក្រណាស់ប៉ា ថ្ងៃណាយើងមានសំណាងដូចពួកគេ! កូនមិនចង់ត្រលប់ទៅផ្ទះវិញ**"។

ជាច្រើនលើកច្រើនសា យើងបានភ្លេចនូវអ្វីដែយើងមាន និងផ្តោតលើអ្វីដែលយើងអត់មាន។ របស់ខ្លះមិនមែនជារបស់មានតម្លៃរបស់អ្នកមានទេ តែវាជារបស់ខាន់បំផុតនៅក្នុងជីវិតរបស់អ្នកផ្សេង (អ្នកក្រ)។ អ្វី។ គឺផ្អែកលើទស្សនៈរបស់មនុស្សប៉ុណ្ណោះ។ អ្នកមានអ្នកក្រមិនអាចសំអាងលើរបស់ទ្រព្យជាប់ខ្លួននោះទេ៕

ផែនទីរាជធានីភ្នំពេញ



- ផ្ទៃដីសរុប = ៦៧៨ គ.ម^{២}
- ប្រជាជន = ១.៩៩៥.៨៨៨ ស្រី ៧៦៥.៩៦៦ (ឆ្នាំ២០១៨)
- ចំនួនគ្រួសារ = ២៧៨.៧៥២
- ដង់ស៊ីតេ = ២.១៣២ នាក់/គម^{២}
- ខណ្ឌ = ១២
- សង្កាត់ = ៩៦
- ភូមិ = ៩០៩